E20 - 16

# រឿងនិទាន ស្តីពីសហគមន៍នេសាទមួយ

MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT




គំរោងការគ្រប់គ្រងជលផលនៅអាងទឹកនៃអាងទន្លេមេគង្គជំហានទី២
ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ
នាយកដ្ឋានជលផល

### រឿងនិទាន

# ស្ដីពី សហគមន៍នេសាទមួយ

ឧបត្ថម្ភដោយ

នាយកដ្ឋានជលផល

គណៈកម្មការទន្លេមេគង្គ

រៀបចំដោយ

**ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃនាយកដ្ឋានជលផល និង**
**គ្រោងការគ្រប់គ្រងជលផលនៅអាងទឹកនៃអាងទន្លេមេគង្គជំហានទី២**
**នៃគណៈកម្មការទន្លេមេគង្គ**


អាស័យដ្ឋានៈ

#១៨៦ មហាវិថីព្រះនរោត្តម ទូរសព្ទ័លេខៈ (៨៥៥-២៣) ២១០ ១៥៤

ខណ្ឌចំការមន ទីក្រុងភ្នំពេញ ទូរសារលេខៈ (៨៥៥-២៣) ២១០ ១៥៤


ខែ កញ្ញា ឆ្នាំ ២០០២

# បុព្វកថា

សៀវភៅរឿងត្លុកដែលនិទានអំពីដំណើរការរៀបចំ និង គ្រប់គ្រងសហគមន៍នេសាទនេះ ត្រូវបានចងក្រងឡើងរួមគ្នាដោយនាយកដ្ឋានជលផល និងគ្រោងការគ្រប់គ្រងជលផលនៅអាងទឹកនៃអាងទន្លេមេគង្គនៅកម្ពុជា ដើម្បីបំពេញនូវសេចក្ដីត្រូវការបន្ទាន់នៅតាមមូលដ្ឋានជាក់ស្ដែង ។ ស្របពេលនឹងកំណែទំរង់វិស័យជលផលរបស់រាជរដ្ឋាភិបាលដែលបានលុប និង កាត់បន្ថយផ្ទៃឡូត៍នេសាទជាង ៥០ ភាគរយ ជូនប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ ការគ្រប់គ្រងតាមបែបសហគមន៍ជាមធ្យោបាយ រឺ ដំណោះស្រាយសមស្របមួយ ដើម្បីប្រើប្រាស់ និង អភិវឌ្ឍន៍ធនធានជលផលឱ្យមាននិរន្តរភាព សមធមិ និង ប្រសិទ្ធិភាព។

យើងខ្ញុំសង្ឃឹមថាសៀវភៅនេះ នឹងបានផ្សព្វផ្សាយទៅដល់ភូមិជាច្រើនដែលគ្មានគំរោងរដ្ឋាភិបាលរឺក្រៅរដ្ឋាភិបាលជួយ ហើយនឹងអាចជួយឱ្យប្រជាជននៅតាមភូមិទាំងនោះ យល់ពីដំណើរការរៀបចំសហគមន៍នេសាទ ដើម្បីជាជំនួយដល់ពួកគេក្នុងការរៀបចំបង្កើតសហគមន៍ដោយខ្លួនឯងបាន ទៅតាមស្ថានភាពជាក់ស្ដែងនៅតាមតំបន់រៀងៗខ្លួន។

ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីផ្ដល់ជាកំលាំងចិត្តដល់អ្នកទាំងឡាយណាដែលចង់បង្កើតសហគមន៍នេសាទឱ្យបន្តធ្វើតាមផែនការរបស់ខ្លួន និង សូមឱ្យអ្នកទាំងនោះមានការអត់ធ្មត់ ការលះបង់ខ្ពស់ ដើម្បីទទួលបានជោគជ័យក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួន។

ភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២

**ប្រធាននាយកដ្ឋានជលផល**

**ណៅ ធួក**

AIDOC
Code: 142-023
Date:
Donated by:

# សេចក្ដីផ្ដើម

នៅចុងឆ្នាំ ២០០០ ផ្ទៃឡូត៍ជាង ៥០ ភាគរយបានត្រូវលប់ និងកាត់បន្ថយ ដើម្បីប្រគល់ឱ្យប្រជានេសាទធ្វើនេសាទជាលក្ខណៈគ្រួសារ និង គ្រប់គ្រងតាមបែបសហគមន៍ ។ ប្រជាពលរដ្ឋនៅតាមភូមិជាច្រើន ចង់បានការគ្រប់គ្រងតាមបែបសហគមន៍នេះ ក៏ប៉ុន្តែពួកគេមិនដឹងពីបែបបទនៃកាបង្កើតសហគមន៍នេសាទនេះទេ ។

សៀវភៅនេះ ត្រូវបានចងក្រងឡើង ដើម្បីបំពេញសេចក្ដីត្រូវការរបស់ពួកគាត់ ជាពិសេសសំរាប់ប្រជានេសាទដែលចង់បង្កើតសហគមន៍នេសាទ នៅតាមតំបន់ឆ្ងាយដាច់ស្រយាលដែលអង្គការ រឺ ស្ថាបន័រដ្ឋាភិបាលមិនអាចទៅជួយដល់ទីកន្លែងបាន ។ សៀវភៅនេះ បានរៀបរាងឡើងជារបៀបរឿងត្លុកដែលនិទាន ស្ដីពីដំណើរការសាមញ្ញនៃការរៀបចំសហគមន៍នេសាទមួយដោយផ្អែកទៅតាមគោលការណ៍ណែនាំបណ្ដោះអាសន្នរបស់នាយកដ្ឋានជលផល ។ រឿងត្លុកនេះ បានបង្ហាញសំខាន់ ពីមូលហេតុដែលនាំអោយប្រជានេសាទចាប់អារម្មណ៍ និង មានគំនិតបង្កើតសហគមន៍នេសាទ ហើយពួកគាត់បានស្រុះស្រួល និង ឯកភាពគ្នារៀបចំបង្កើតសហគមន៍នេះឡើង នៅក្នុងតំបន់របស់ពួកគាត់ ។ ព្រមជាមួយនេះ ផែនការគ្រប់គ្រងសហគមន៍ក៏ត្រូវបានធ្វើ និង អនុវត្តដោយពួកគាត់ផ្ទាល់ ដោយមានការគាំទ្រ ទំនាក់ទំនង និងសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរដែនដី និងស្ថាបន័ជំនាញដែលពាក់ពន្ធ័ ដើម្បីសំរេច នូវគោលដៅនៃការគ្រប់គ្រង និង ប្រើប្រាស់ធនធានជលផលឱ្យមាននិរន្តភាព ។

នៅក្នុងសៀវភៅនេះ ក៏បានភ្ជាប់នូវបញ្ជីគំរោង និង អង្គការ ដែលធ្វើការជាប់ទាក់ទងជាមួយការអភិវឌ្ឍន៍សហគមន៍នេសាទ នៅតាមបណ្ដាខេត្ត ដើម្បីផ្ដល់ជាពត៌មានផងដែរ ។ លើសពីនេះ ក៏មានគោលការណ៍ណែនាំសាមញ្ញសំរាប់ធ្វើលក្ខនិកៈ និងបទបញ្ញតិ និង គំរូនៃការធ្វើផែនការសកម្មភាពនៃសហគមន៍ដែលធ្វើដោយសហគមន៍នេសាទអាងទឹកបឹងជន្លេន នៅស្រុកមុខកំពូល ខេត្តកណ្ដាល ភ្ជាប់ជាមួយផងដែរ ។

# វគ្គទី ១

# មូលហេតុ

# ដែលនាំអោយមានគំនិតបង្កើតសហគមន៍




